# បទឧទ្ទេសនាម

## របស់

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ដើម្បីពិភាក្សា និង អនុម័ត សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

*រដ្ឋសភា, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២១*

ខ្ញុំបាទសូមគោរព ៖

- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;
- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី ១ រដ្ឋសភា;
- លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី ២ រដ្ឋសភា;
- សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម ព្រមទាំងគណៈកម្មការពាក់ព័ន្ធទាំងអស់នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ ដើម្បីពិនិត្យ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២** ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយគោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភារួចហើយ, ហើយ **ឯកឧត្តម ឈាង វុន** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភា ក៏បានរាយការណ៍បន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញ អំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាព និង ខ្លឹមសាររួម ព្រមទាំងរចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះ; ដូច្នេះ នៅពេលនេះ ខ្ញុំបាទសូមអនុញ្ញាតធ្វើបទឧទ្ទេសនាម

ដោយសង្ខេបខ្លះដើម្បីចំណេញពេល ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬ សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តម ឈាង វុន** បានរាយការណ៍ជូនអង្គរដ្ឋសភា មុននេះ ។

## I. អំពីបរិការណ៍ និង ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍បច្ចុប្បន្នដែលកម្ពុជាកំពុងស្ថិតក្នុងវិបត្តិជំងឺកូវីដ-១៩ នៅឡើយ បន្ទាប់ពី **ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១** និង ការបន្តរីករាលដាលនៃមេរោគក្លូរ៉ូណាបំប្លែងថ្មី ដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់សុខភាព, សង្គម, សេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងកំពុងដាក់សម្ពាធកាន់តែធ្ងន់មកលើថវិកាជាតិ ។ រាជរដ្ឋាភិបាលបាន និង កំពុងបញ្ចេញចំណាយអន្តរាគមន៍យ៉ាងច្រើន ដើម្បីទប់ទល់នឹងវិបត្តិនេះ ព្រមជាមួយនឹងការគ្រោងដាក់ចេញនូវ **"ក្របខ័ណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** សំដៅលើកស្ទួយជីវភាពរបស់ប្រជាជនទូទៅ ។ ទន្ទឹមនេះ, ថវិកាឆ្នាំ ២០២២ ក៏ជាថវិកាឆ្នាំទី ៤ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ដែលតាមរយៈនេះ, រាជរដ្ឋាភិបាលត្រូវបន្តខិតខំសម្រេចឱ្យបាននូវអាទិភាពគោលនយោបាយ និង គោលដៅអភិវឌ្ឍន៍សំខាន់ៗជាសារវន្ត, ដូចមានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**, នៅលើមាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និង ការជំរុញការអភិវឌ្ឍ ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលជាច្រើនដែលសម្រេចបានកន្លងមក, ទាំងខាងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ពិសេសគឺ សន្តិភាព និង ស្ថិរភាពនយោបាយដ៏រឹងមាំជាប់មិនដាច់ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និង មិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍជាតិ និង ភាពសុខក្សេមក្សាន្តរបស់ប្រជាជន ។ មួយវិញទៀត, ថវិកាឆ្នាំ ២០២២ ក៏ជាថវិកាដែលត្រូវធានាជោគជ័យនៃការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និង ជោគជ័យនៃការបំពេញកាតព្វកិច្ចតំបន់ និង អន្តរជាតិរបស់កម្ពុជា ពិសេសគឺ ការធ្វើជាម្ចាស់ផ្ទះ និង ជាប្រធានអាស៊ាន ។

អាស្រ័យដោយអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុអំពីសេចក្តីព្រាងច្បាប់នេះ បានគូសវាសរៀបរាប់ហើយអំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២ ក៏ដូចជាអំពីបញ្ហាប្រឈម និង ហានិភ័យ, ទាំងផ្នែកក្រៅប្រទេស, ទាំងផ្នែកក្នុងប្រទេស, ព្រមទាំងអំពីវិធានការគោលនយោបាយមុតស្រួចមួយចំនួន ដែលត្រូវបានដាក់ចេញ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

និង ដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ប្រកបដោយចីរភាព និង បរិយាប័ន្ន, ដូចនេះ, ខ្ញុំបាទសូមជម្រាបជូនជាសង្ខេបថា តាមការវាយតម្លៃពាក់កណ្តាលឆ្នាំកន្លងមក, សេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ២០២១ ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើនក្នុងអត្រា ២,៤% ខណៈដែលការវាយតម្លៃឡើងវិញរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗនាពេលថ្មីៗនេះ ក៏បាន យល់ស្របលើអត្រាកំណើនប្រហាក់ប្រហែលគ្នា គឺក្នុងរង្វង់ប្រមាណ ២% ។ ដោយឡែក, សម្រាប់ឆ្នាំ ២០២២ សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ **៤,៨%** ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថា នឹងកើនឡើងដល់ **១ ៨៤២** ដុល្លារអាមេរិក ធៀបនឹង **១ ៧៣០** ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១ ។ ប៉ុន្តែ, សេដ្ឋកិច្ចកម្ពុជាក៏នៅ តែអាចជួបប្រទះនឹងបញ្ហាប្រឈម និង ហានិភ័យ, ទាំងទិដ្ឋភាពខាងក្នុង និង ខាងក្រៅ, ដែល អាចនឹងប៉ះពាល់ដល់ចីរភាពនៃកំណើន និង និរន្តរភាពនៃការអភិវឌ្ឍប្រទេស ។ ដូច្នេះ, ដើម្បី ត្រៀមខ្លួនដោះស្រាយហានិភ័យចម្បងៗជាយថាហេតុ, រាជរដ្ឋាភិបាលកម្ពុជានឹងជំរុញអនុវត្ត **"ក្របខ័ណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅ ជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** ដែលនឹងត្រូវបានដាក់ ចេញក្នុងពេលឆាប់ៗខាងមុខនេះ ដោយឈរលើសសរស្តម្ភចំនួន ៣ (ឬហៅថា 3Rs) គឺ៖

**សសរស្តម្ភទី១-ការស្តារ** (Recovery) តាមរយៈការកសាងមូលដ្ឋានរឹងមាំ សម្រាប់ជំរុញ សេដ្ឋកិច្ចឱ្យវិលទៅស្ថិតលើមាគ៌ានៃកំណើនឡើងវិញ ដោយផ្តោតលើការធានាសុវត្ថិភាព, ការគ្រប់គ្រងផលប៉ះពាល់, ការរក្សាលំនឹង និង ការធ្វើឱ្យរស់រវើកឡើងវិញ នូវធុរកិច្ចដែលមាន សក្តានុពល ជាពិសេស ក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំង និង ការបង្កើតការងារបន្ថែម ឱ្យបានច្រើន និង ឆាប់រហ័ស សំដៅលើកស្ទួយជីវភាពប្រជាជន;

**សសរស្តម្ភទី២-ការកែទម្រង់** (Reform) តាមរយៈការបន្តដាក់ចេញ នូវវិធានការ កែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមានជាអាទិ៍: ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និង កិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការវិនិយោគ និង ធុរកិច្ច, ការជំរុញ និង ការអភិវឌ្ឍ ឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និង វិស័យឯកជន; និង

**សសរស្តម្ភទី៣-ការកសាងភាពធន់** (Resilience) តាមរយៈការពង្រឹងការត្រៀមខ្លួន ដើម្បី ឆ្លើយតបទៅនឹងជំងឺ ឬ ស្ថានភាពស្រដៀងគ្នា ដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្តោតលើ ការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និង ប្រព័ន្ធគាំពារសង្គម ដែលរឹងមាំ និង មានប្រសិទ្ធភាព ក៏ដូចជា ផ្តោតលើវិស័យគន្លឹះមួយចំនួនទៀតដែលមានសារៈសំខាន់សម្រាប់ការធានានូវចីរភាព និង បរិយាប័ន្ន នៃការស្តារ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

## II. អំពីអភិក្រម និង គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០២២

នៅក្នុងបរិការណ៍រួមដូចបានគូសបញ្ជាក់ខាងលើ, ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **<u>អភិក្រមគ្រឹះ</u>** ជាយុទ្ធសាស្ត្រសំខាន់ចំនួន ៥ រួមមាន៖

(១)-ទប់ទល់ការរាតត្បាត និង កាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ ហើយបន្សាំខ្លួនរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងគន្លងប្រក្រតីថ្មី;

(២)-អនុវត្តផែនការស្តារសេដ្ឋកិច្ចឡើងវិញ ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងរង្វង់ ៤,៨% និង បន្តបង្កើតការងារជូនប្រជាជន ជាពិសេស ស្រទាប់យុវជន ព្រមទាំងផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញ និង បង្កើនចំណូលថវិកាជាតិ;

(៣)-ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស គឺធានាគ្រប់គ្រងបាននូវអតិផរណា និង ធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ;

(៤)-បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និង បន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងភាពប្រកួតប្រជែង និង ពិពិធកម្មសេដ្ឋកិច្ច សំដៅធានាស្ថិរភាពកំណើន, គាំទ្រដល់ការស្តារសេដ្ឋកិច្ច និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ព្រមទាំងពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និង សមត្ថភាពនៃវិស័យសាធារណៈ ក្នុងគោលដៅពង្រីកវិសាលភាព និង ពង្រឹងគុណភាពនៃសេវាសាធារណៈ និង សេវាយុត្តិធម៌; និង

(៥)-ធានាអនុវត្តឱ្យបានជោគជ័យ នូវរបៀបវារៈនៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យពិសេសការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏ដូចជាការបំពេញកាតព្វកិច្ចតំបន់ និង អន្តរជាតិរបស់កម្ពុជា ពិសេសក្នុងនាមជាប្រធានអាស៊ាន ។

ផ្អែកលើគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រខាងលើ, ថវិកាឆ្នាំ ២០២២ ក៏ត្រូវបានរៀបចំឡើងដោយឈរលើ **អភិក្រម និង គោលការណ៍បច្ចេកទេសសំខាន់ៗ** ចំនួន ៧ ទៀត រួមមាន៖ (១)-**ការធានាចីរភាព និង សមិទ្ធកម្មនៃចំណូល**, (២)-**ការធ្វើវិចារណកម្មលំដាប់អាទិភាព**, (៣)-**ការយកចិត្តទុកដាក់លើមនុស្ស**, (៤)-**ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព**, (៥)-**ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត**, (៦)-**ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និង ការវិភាជថវិកា**, និង (៧)-**ការរក្សាតុល្យភាព និង ចីរភាពថវិកា** ។

## III. អំពីក្របខ័ណ្ឌថវិកាឆ្នាំ ២០២២

ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ត្រូវបានកំណត់ដូចតទៅ ៖

១-ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ចំណូលក្នុងប្រទេសថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **២៥,៦ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៦,៣ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **២០,៦១%** នៃ ផសស, **មានកំណើន ១៩,៣%** ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង **១៩,៥៦%** នៃ ផសស ដែល**មានកំណើនចំនួន ១,១៤ ពិន្ទុភាគរយនៃ ផសស** ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២១ ពោលគឺ នឹងសម្រេចបានខ្ពស់ជាង **គោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ** ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម **០,៣ ពិន្ទុភាគរយ** នៃ ផសស ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ ២០១៩-២០២៣ ។

២-ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **៣៤,៧ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៨,៥ ប៊ីលានដុល្លារអាម៉េរិក**, ស្មើនឹង **២៧,៩៥%** នៃ ផសស, **មានកំណើន ៨,៤%** ធៀបនឹងច្បាប់ឆ្នាំ ២០២១; ក្នុងនោះ ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងចំនួន **២០,៨ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៥,១ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា ១៦,៧៩% នៃ ផសស, **កើនឡើង ១១,២%** ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។

៣- គុល្យភាពរួមនៃថវិកាឆ្នាំ ២០២២

នៅក្នុងក្របខ័ណ្ឌថវិការដ្ឋ ឬ ថវិកាជាតិ, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ **២,៧៧%** នៃ ផសស នៅឆ្នាំ ២០២២ ធៀបនឹងច្បាប់ឆ្នាំ ២០២១ ដែលមានចំនួន **២,១៥%** នៃ ផសស ។ ជាលទ្ធផល, ឱនភាពថវិកាជាតិសរុប នឹងមានទំហំស្មើនឹង **-៧,៣៤%** នៃ ផសស គឺថយចុះពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០២១ ដែលស្មើនឹង **-៩,១៧%** នៃ ផសស ។ ឱនភាពនេះ ត្រូវបានបំពេញតុល្យភាពដោយ ៖ (១). **ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ **៤,៦៨%** នៃ ផសស; (២). **មូលនិធិទ្រទ្រង់ថវិកា** ក្នុងទំហំ **១,០២%** នៃ ផសស; (៣). **ការបោះផ្សាយលក់មូលបត្ររដ្ឋ** ក្នុងទំហំ ០.៩៨% នៃ ផសស ស្មើនឹង **១ ២១៩ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៣០០ លានដុល្លារអាម៉េរិក**; និង (៤). ប្រាក់បញ្ញើរាជរដ្ឋាភិបាល ក្នុងទំហំ **១,៦៤%** នៃ ផសស ស្មើនឹង **២ ០៣២ ប៊ីលានរៀល**, សមមូលនឹង **៥០០ លានដុល្លារអាម៉េរិក** ដែលត្រូវបានគ្រោងយកមកប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយ និង វិធានការរក្សាលំនឹង ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជាពិសេសសម្រាប់អនុវត្ត "**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និង**

កម្មវិធីស្ដារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លង-ប្រក្រតីភាពថ្មី" ។

## IV. អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២២ មានគោលដៅប្រមូលចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យមានទំហំស្មើនឹង **២៣,៥ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៥,៨ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **១៨,៩%** នៃ ផសស, គឺមានកំណើន ១៧,៧% ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។ ក្នុងក្របខ័ណ្ឌនេះ, ខ្លឹមសារពិស្ដារនៃសេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងច្បាប់នេះ បានរៀបរាប់រួចហើយអំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំងគោលដៅចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងអំពីគោលដៅចំណូលមូលធន, ទាំងចំណូលមូលធនក្នុងប្រទេស និង ចំណូលមូលធនក្រៅប្រទេស ។ ដូច្នេះ, ខ្ញុំបាទសូមមិនធ្វើការអធិប្បាយបន្ថែមទៀតទេ ។

### ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

#### ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

**ក-១- <u>អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ</u>**

ថវិកាថ្នាក់ជាតិឆ្នាំ ២០២២ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតក្នុងកម្រិត ប្រមាណ **១៩,១ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៤,៧ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **១៥,៣៩%** នៃ ផសស, **គឺមានកំណើន ៩,៥%** ធៀបនឹងច្បាប់ឆ្នាំ ២០២១ ដែលក្នុងនោះ ៖

ក.១.១-<u>ចំណាយលើបន្ទុកបុគ្គលិក</u> ត្រូវបានគ្រោងប្រមាណ **៨,៦ ទ្រីលានរៀល**, មានសមាមាត្រស្មើនឹង **៤៥,៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ**, ត្រូវជា **៦,៩៧%** នៃ ផសស, **មានកំណើន ១,០%** ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។ ចំណាយបន្ទុកបុគ្គលិកនេះ ត្រូវបានគ្រោងដោយរក្សាកម្រិតប្រាក់បៀវត្ស មន្ត្រីរាជការស៊ីវិល និង កម្លាំងប្រដាប់អាវុធឆ្នាំ ២០២២ **ស្មើនឹងកម្រិតឆ្នាំ ២០២១** ដើម្បីសន្សំថវិកាសម្រាប់បន្តការងារអន្តរាគមន៍ផ្នែកសុខាភិបាល និងសង្គម ពិសេសគឺការបង្កើនកញ្ចប់ថវិកាជួយជនក្រីក្រ (ក្រ១ និង ក្រ២) និងជនងាយរងគ្រោះ ឱ្យបានដល់ ៩ ខែ ជាបន្តទៀត នៅក្នុងឆ្នាំ២០២២។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងបន្តធានាបាននូវការបើកផ្ដល់បៀវត្សជូនមន្ត្រីរាជការឱ្យបានទាន់ពេល គឺ **២ ដង ក្នុង ១ ខែ** ។ ចំពោះប្រាក់សោធននិវត្តន៍ ក៏ត្រូវបានគ្រោងថវិកាចំនួន **៣០ ប៊ីលានរៀល** សម្រាប់ការកាត់-

បន្តយកម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកចូលនិវត្តន៍ចាស់ និង អ្នកចូលនិវត្តន៍ថ្មី ជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធផងដែរ ។

ក.១.២-ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវបានគ្រោងប្រមាណ **១០,៥ ទ្រីលានរៀល, មានសមាមាត្រស្មើនឹង ៥៤,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ**, ត្រូវជា ៨,៤២% នៃ ផសស, គឺមានកំណើន **១៧,៨%** ធៀបនឹងច្បាប់ឆ្នាំ ២០២១ ។ **ការគ្រោងកើនឡើងនេះ គឺសម្រាប់ការអនុវត្តអាទិភាពចម្បង និង សំខាន់មួយចំនួន រួមមាន៖ ការបន្តអន្តរាគមន៍ប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់, ការធ្វើជាប្រធានអាស៊ាន និង ជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និង កិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងអាទិភាពមួយចំនួនទៀត។** ជាក់ស្តែង, វិស័យសង្គមកិច្ចនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី ១ ដោយក្នុងនោះ អាទិភាពចំណាយត្រូវបានផ្តោតទៅលើ៖ **ការបន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩**; ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និង ការពង្រីកការទទួលបានសេវាសុខាភិបាល ជាពិសេស សម្រាប់ប្រជាជនក្រីក្រ, ក្រុមជនងាយរងគ្រោះ, ស្ត្រី និង កុមារ តាមរយៈការបន្តគាំទ្រដល់កម្មវិធីមូលនិធិសមធម៌ និង ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល; ការបន្តផ្តល់កញ្ចប់ថវិកាប្រតិបត្តិការជូនដល់មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព; ការបន្តគាំទ្រគោលនយោបាយគាំពារសង្គម, ការបន្តគាំទ្រដល់ការពង្រីកការទទួលបានសេវាអប់រំ និង ការលើកកម្ពស់គុណភាពអប់រំ ព្រមទាំងការអប់រំកាយ និងកីឡា ជាពិសេស ការបន្តផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ; ការបង្កើនថវិកាដំណើរការសាលារៀន; ការបន្តពង្រឹងសាលារៀនជំនាន់ថ្មី និង ការកសាងសាលារៀន; ការគាំទ្រដល់ចំណាយប្រតិបត្តិការមត្តេយ្យសហគមន៍; ការអភិវឌ្ឍជំនាញដែលឆ្លើយតបនឹងតម្រូវការទីផ្សារ ជាពិសេស នៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និង ការអភិវឌ្ឍវិស័យការងារ; ការការពារ និង អភិរក្សធនធានធម្មជាតិ; ការអភិរក្ស និង ការអភិវឌ្ឍវប្បធម៌ជាតិ និង សុខដុមនីយកម្មសាសនា ។

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

ចំណាយមូលធនថ្នាក់ជាតិ ត្រូវបានគ្រោងប្រមាណ **១៣ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៣,៣ ប៊ីលានដុល្លារអាមេរិក, មានកំណើន ៣,២២% ធៀបនឹងច្បាប់ឆ្នាំ ២០២១, មានសមាមាត្រស្មើនឹង ៤១,៣% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ១០,៨៤% នៃ ផសស**, ដែលក្នុងនោះ ៖

(១)-**គម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ ត្រូវបានគ្រោង**ក្នុងទំហំប្រមាណ **៤,៩៧%** នៃ ផសស, **មានការថយចុះ ៣,៤%** ធៀបនឹងច្បាប់ឆ្នាំ ២០២១

ទៅតាមលទ្ធភាពថវិកា ក្នុងពេលដែលចំណូលមានការថមថយដោយសារផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ ។

(២)-**គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** មានកំណើន **៦,៤%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១, ត្រូវជា **៤,៦៨%** នៃ ផសស ដែលស្មើនឹងប្រមាណ **១៦,៧% នៃចំណាយថវិការដ្ឋសរុបឆ្នាំ** ២០២២ ។

(៣)-**ការកំណត់ពិតាននៃការខ្ចី:** សម្រាប់ឆ្នាំ ២០២២, រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចី ដូចតទៅ៖ (ទី១)-**គ្រោងធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង** ចំនួន **៣០០ លានដុល្លារអាម៉េរិក** ដើម្បីធ្វើហិរញ្ញប្បទានគាំទ្រគម្រោងវិនិយោគសាធារណៈ សំដៅលើកស្ទួយកំណើន និង ផលិតភាពសេដ្ឋកិច្ច និង (ទី២)- **ខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍ក្នុងកម្រិត ១ ៦០០ លាន SDR** ។ ខ្ញុំសូមគូសបញ្ជាក់ថា, ជារួម, **ការបោះផ្សាយលក់មូលប័ត្ររដ្ឋ និង ទំហំនៃការខ្ចីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌករដល់កម្ពុជាទេ ពោលគឺជាទិដ្ឋភាពបច្ចេកទេសស្ថានភាពបំណុលសាធារណៈកម្ពុជានៅតែត្រូវបានវាយតម្លៃថា មាន "ចីរភាព" និង "ហានិភ័យកម្រិតទាប" ដដែល ដោយរាល់សូចនាករគន្លឹះៗនៃការគ្រប់គ្រងបំណុលរបស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់** ។

## V. អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មានឋិនភាពថវិកាចំនួនប្រមាណ **១,៣ ទ្រីលានរៀល** ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់-ជាតិ ហើយត្រូវបានបែងចែកលម្អិតជូនទៅថ្នាក់រដ្ឋបាលនីមួយៗ ។ ដូចគ្នានឹងថ្នាក់ជាតិដែរ, ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងឆ្នាំ ២០២២ នេះ ត្រូវបានរក្សាស្មើនឹងកម្រិតឆ្នាំ ២០២១ ។

## VI. និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលស្នើធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដើម្បីគោលដៅដូចខាងក្រោម ៖

**ទី១**-ឥណទានទូទាត់ចំណាយកម្មវិធីប្រយុទ្ធ និង ទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ ចំនួន ៣ ៩៤៣ ០៥០ លានរៀល, សមមូលប្រមាណ ៩៧០ លានដុល្លារអាម៉េរិក ។

**ទី២**-ឥណទានទូទាត់ចំណាយកម្មវិធីជំនួយសង្គមជួយជនក្រីក្រ និង ជនងាយរងគ្រោះ ចំនួន ៣៦២ ៥៥១ លានរៀល, សមមូលប្រមាណ ៩០ លានដុល្លារអាម៉េរិក ។

**ទី៣**-ឥណទានទូទាត់ចំណាយលើការទិញយកមន្ទីរពេទ្យស្ត្រីនគរទេព ចំនួន ៦២ ៥៣១,២ លានរៀល ដោយប្រើប្រភពចំណូលពីសប្បុរសជន ប៉ុន្តែមានការចាំបាច់ត្រូវឆ្លុះបញ្ចាំងក្នុងច្បាប់ថវិកា ។

**ទី៤**-ឥណទានទូទាត់ចំណាយសម្រាប់ការបង្វិលសងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ ចំនួន ១០៤ ០០០ លានរៀល ។

**ទី៥**- ឥណទានចំនួន ៥០ លានដុល្លារអាម៉េរិក សម្រាប់អនុញ្ញាតផ្តល់ឱ្យអគ្គិសនីកម្ពុជា (EDC) ខ្ចី ដើម្បីដោះស្រាយតម្រូវការថាមពលអគ្គិសនីរយៈពេលវែង ។

**ទី៦**-ឥណទានពីអតិរេករបស់រដ្ឋបាលឃុំ-សង្កាត់ ចំនួន ១៩៤ ៤៩៩,៧ លានរៀល ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ។

## VII. សេចក្តីសន្និដ្ឋាន

សរុបមក, ថវិកាឆ្នាំ ២០២២ អាចត្រូវបានសន្និដ្ឋានជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច ហើយអាចប្រសិទ្ធនាមបានថា ជា **"ថវិកាសម្រាប់បន្តការប្រយុទ្ធប្រឆាំង និង ការកសាងសមត្ថភាពរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី"** ដែលបម្រើឱ្យគោលដៅយុទ្ធសាស្ត្រ ៣ យ៉ាង គឺ៖ **(១)-ការបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន; (២)-ការបន្តខិតខំរក្សាលំនឹងសង្គម-សេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ប្រជាជន; និង (៣)-ការតម្រង់ធនធានឆ្ពោះទៅស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ** ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ, **សូមសម្តេចអគ្គមហាពញាចក្រី** និង **អង្គសភាទាំងមូល** មេត្តាពិនិត្យ និង ផ្តល់ការអនុម័តលើ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២** ដោយអនុគ្រោះ ។

សូមអរគុណ!